# សេចក្ដីសំរេច

# ស្ដីពី

# ការបង្កើតគណៈកម្មការជាតិពិភាក្សាផ្ដល់យោបល់ និងដោះស្រាយបាតុភាពលើការទារគ្រប់គ្រងតំបន់ការពារធម្មជាតិ

ក្រសួងបរិស្ថាន
នាយកដ្ឋានការពារ.អភិរក្ស.ធម្មជាតិ
ចូល លេខ...591B... .ធ.បស្ហ
ថ្ងៃទី..09..ខែ..08..ឆ្នាំ2000

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៩ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការជាតិពិភាក្សាផ្តល់យោបល់ និង ដោះស្រាយបាតុភាពលើការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និង ការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញសេចក្តីប្រកាសលេខ ០១ ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីវិធានការត្រួតត្រា និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើរបស់រាជរដ្ឋាភិបាល
- បានឃើញសេចក្តីប្រកាសលេខ ០៦ ប្រក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យ ក្នុងបញ្ហាទន្រ្ទានកាន់កាប់ដីធ្លី របស់រាជរដ្ឋាភិបាល
- យោងសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការជាតិអន្តរក្រសួងមួយ ដើម្បីពិភាក្សាផ្តល់យោបល់ និង ដោះស្រាយបាតុភាពលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលមានសមាសភាពដូចតទៅ ៖

| | | | |
|---|---|---|---|
| ១_ ឯកឧត្តម | **ម៉ុក ម៉ារ៉េត** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ២_ ឯកឧត្តម | **គៀង វ៉ាង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣_ ឯកឧត្តម | **ចំនួ គុងអ៊ីច** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤_ ឯកឧត្តម | **លី ធុជ** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៥_ ឯ.ឧ.ឧត្តមសេនីយ៍ឯក | **ម៉ុល សារឿន** | អគ្គមេបញ្ជាការរងនៃបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៦_ ឯ.ឧ.ឧត្តមសេនីយ៍ឯក | **ហុក ឡង់ឌី** | អគ្គនាយកនគរបាលជាតិ | សមាជិក |
| ៧_ ឯ.ឧ.ឧត្តមសេនីយ៍ឯក | **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៨_ ឯកឧត្តម | **ស៊ិន សារុន** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩_ ព្រះអង្គម្ចាស់ | **ស៊ីសុវត្ថិ ជីវ័ណ្ណារឬទ្ធិ** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១០_ ឯកឧត្តម | **អ៊ុំ ម៉ុនធឿន** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១១_ ឯកឧត្តម | **កែវ ខេមរា** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ១២_ ឯកឧត្តម | អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ | | សមាជិក |

**ប្រការ ២** : គណៈកម្មការជាតិអន្តរក្រសួងនេះ មានភារកិច្ច និងបេសកកម្មដូចតទៅ ៖

- ចូលរួមពិភាក្សាផ្តល់យោបល់ លើរាល់ការងារពាក់ព័ន្ធដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- ចូលរួមពិភាក្សាផ្តល់យោបល់ លើការងារអភិរក្ស និង អភិវឌ្ឍន៍តំបន់ការពារធម្មជាតិ
- លើកវិធានការទប់ស្កាត់ និង ដោះស្រាយជាបន្ទាន់ នូវរាល់សកម្មភាពអនាធិបតេយ្យ ដែលកើតឡើងក្នុងតំបន់ការពារធម្មជាតិ
- ចូលរួមវាយតម្លៃ និង ពិភាក្សាផ្តល់យោបល់ លើរាល់ការងារពាក់ព័ន្ធដល់ការកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិ

**ប្រការ ៣** : គណៈកម្មការជាតិអន្តរក្រសួងនេះ ត្រូវបង្កើតអនុគណៈកម្មការចំរុះមួយនៅតាមបណ្តាខេត្ត-ក្រុង ពាក់ព័ន្ធដែលមានអភិបាលខេត្តរង ០១ រូប ជាប្រធាន ដើម្បីជាជំនួយការលើការបំពេញភារកិច្ចនៅតាមបណ្តាខេត្ត-ក្រុង ដែលមានតំបន់ការពារធម្មជាតិ ។

**ប្រការ ៤** : គណៈកម្មការជាតិអន្តរក្រសួងនេះ មានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីស្នាក់ការអចិន្ត្រៃយ៍នៅទីស្តីការក្រសួងបរិស្ថាន និង ប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ។

**ប្រការ ៥** : សមាជិកគណៈកម្មការជាតិតំណាងអោយក្រសួង-ស្ថាប័ន ខេត្ត-ក្រុងនានា និងអនុគណៈកម្មការ ខេត្ត-ក្រុងត្រូវចូលរួមទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ចដែលបានចែងក្នុងប្រការ ២ ខាងលើនិងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការជាតិអន្តរក្រសួង ហើយរាយការណ៍ពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត_ក្រុង អនុគណៈកម្មការ និង សមាសភាពដែលមានចែងក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០០*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- *ខុទ្ទកាល័យព្រះមហាក្សត្រ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *ឯកសារ_កាលប្បវត្តិ*